# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

98/13

ក្រុមប្រឹក្សាជំនុំជម្រះ

## នាមនាមប្រជារាស្ត្រខ្មែរ

### តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៩០

ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០

សាលដីកា

លេខ: ២៣៣

ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំពីរ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៤១ "ក" ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៩០ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ របស់តុលាការកំពូល។

<u>ពីបទ:</u> ជួញដូរមនុស្ស ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃខែ០៧ ខែសីហា ឆ្នាំ២០០៦ បទល្មើស ព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់ និងលក់ ដូរមនុស្ស និងអំពើធ្វើអាជីកម្មលើមនុស្ស។

១-ជនជាប់ចោទឈ្មោះ [redacted] ធីយ៉េវ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ២២ឆ្នាំ ជាតិវៀតណាម កើតនៅប្រទេសវៀតណាម សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះជួលនៅផ្សារ ដើមគរ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ របរនៅផ្ទះ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្តីឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន។ ចាប់ខ្លួនថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

-មានមេធាវីលោកស្រី [redacted] យកហៀប



Scanned by CamScanner

២-ជនជាប់ចោទឈ្មោះ [redacted] ធី "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤៨ឆ្នាំ ជាតិវៀតណាម កើតនៅស្រុកក្រគរ ខេត្តពោធិ៍សាត់ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ មុខរបរ[illegible] ឪពុកធម៌ឈ្មោះ [redacted] "រ" ម្តាយឈ្មោះ[redacted]"រ" ប្តីឈ្មោះ[redacted] មានកូនបួននាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

-មានមេធាវីលោកស្រី [redacted]វីមានចំប៉ា

៣-ជនជាប់ចោទឈ្មោះ [redacted]Heninz "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៦១ឆ្នាំ ជាតិអាឡឺម៉ង់ កើតនៅប្រទេសអាឡឺម៉ង់ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៦E, ផ្លូវ២៧៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ របររកស៊ីគ្រូបង្រៀន ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ[redacted] "រ" នៅរស់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦។

-មានមេធាវីលោកស្រី [redacted] យក់ហៀប

-អ្នកបកប្រែភាសាលោក [redacted] គន្ធី

៤-ជនជាប់ចោទឈ្មោះ [redacted] ហុងវីង "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២០ឆ្នាំ ជាតិវៀតណាម កើតនៅប្រទេសវៀតណាម សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះជួល ផ្លូវ២៣០ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ របររកស៊ីជាងម៉ូតូ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted]"រ" ប្រពន្ធឈ្មោះ[redacted] ទោសពីមុនគ្មាន។ ចាប់ខ្លួនថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦។

-មានមេធាវីលោកស្រី [redacted] វីមានចំប៉ា

ពីបទ៖ ប្រព្រឹត្តអំពើអនាចារលើកុមារ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែទី០៧, ០៨ ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់ និងលក់ដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស។

៥-ជនជាប់ចោទឈ្មោះ[redacted]Heninz "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៦១ឆ្នាំ ជាតិអាឡឺម៉ង់ កើតនៅប្រទេសអាឡឺម៉ង់ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៦E, ផ្លូវ២៧៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ របររកស៊ីគ្រូបង្រៀន ឪពុកឈ្មោះ[redacted] "ស" ម្តាយឈ្មោះ [redacted]"រ" នៅរស់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦។

៦-ជនជាប់ចោទឈ្មោះ [redacted]Thomas ភេទប្រុស អាយុ៤២ឆ្នាំ ជាតិអាឡឺម៉ង់ កើតនៅប្រទេសអាឡឺម៉ង់ ទីលំនៅសព្វថ្ងៃផ្ទះលេខ៣៦E, ផ្លូវ២៧៨ សង្កាត់បឹងកេងកង១

118

98/11

ខណ្ឌចំការមន ក្រុងភ្នំពេញ របររកស៊ីគ្រូបង្រៀន ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

-ជនរងគ្រោះ៖

១-ឈ្មោះ [redacted] ចាន់ធី ភេទស្រី អាយុ១២ឆ្នាំ ជាតិវៀតណាម កើតនៅប្រទេសឡាវ ទីលំនៅបច្ចុប្បន្នភូមិដើមចាន់ [redacted]។

២-ឈ្មោះ [redacted] ចាន់ថា ភេទស្រី អាយុ១៤ឆ្នាំ ជាតិវៀតណាម កើតនៅប្រទេសឡាវ ទីលំនៅបច្ច[redacted]

៣-ឈ្មោះ [redacted] ធិគីមយ៉ុង ភេទស្រី អាយុ១៣ឆ្នាំ ជាតិវៀតណាម ទីកន្លែងកំណើត សង្កាត់ច្បារ[redacted]២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ។

៤-ឈ្មោះ [redacted] យីវ ភេទស្រី អាយុ១៤ឆ្នាំ ជនជាតិវៀតណាម កើតនៅប្រទេសវៀតណាម ទីលំនៅបច្ចុប្បន្ន[redacted]។

មានមេធាវី [redacted] ផាឌិត និង [redacted]ណែត ការពារឱ្យជនរងគ្រោះ

-កាលពីខែ០៧,០៨ ឆ្នាំ២០០៦ នៅក្រុងភ្នំពេញ មានករណីជួញដូរមនុស្សដែលបង្កឡើងដោយឈ្មោះ [redacted] ធីយីវ, ឈ្មោះ [redacted] ហុងវីង, ឈ្មោះ លឹម ទី, ឈ្មោះ [redacted] Heninz និងឈ្មោះ [redacted] Thomas ទៅលើកុមារីឈ្មោះ [redacted] ចាន់ថា, ឈ្មោះ [redacted] ចាន់ធី និងឈ្មោះ [redacted] ធីគីមធី ដោយមានការឃុំទុក(រួមភេទ)ក្នុងផ្ទះរយៈពេល០១អាទិត្យ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖

១-ចោទប្រកាន់ឈ្មោះ [redacted] heninz ភេទប្រុស អាយុ៦១ឆ្នាំ, ឈ្មោះ [redacted] ហុងវីង ភេទប្រុស អាយុ២០ឆ្នាំ, ឈ្មោះ [redacted] យីវ ភេទស្រី អាយុ២១ឆ្នាំ, ឈ្មោះ [redacted] ទី ភេទស្រី អាយុ៤៦ឆ្នាំ ពីបទជួញដូរមនុស្សនៅភ្នំពេញ កាលពីខែកក្កដា,សីហា ឆ្នាំ២០០៦ តាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ពង្រាត់លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស។ ឈ្មោះ [redacted] Heninz ភេទប្រុស អាយុ៦១ឆ្នាំ, ឈ្មោះ [redacted] homas ភេទប្រុស អាយុ៤២ឆ្នាំ ពីបទ៖ ប្រព្រឹត្តអំពើអនាចារលើកុមារ ប្រព្រឹតនៅក្រុងភ្នំពេញ កាលពីខែកក្កដា ខែសីហា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើធ្វើអាជីវកម្មលើមនុស្ស។

២-បង្គង់បណ្តឹងលើគូកនពីបទជួញដូរមនុស្សនៅភ្នំពេញ កាលពីខែកក្កដា, សីហា ឆ្នាំ២០០៦ តាមមាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ពង្រាត់លក់ដូរមនុស្ស និងអំពើធ្វើ អាជីវកម្មលើមនុស្ស។

/119

98
11

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៤ "ខ" ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច៖

១-ផ្តន្ទាទោស៖

ក-ឈ្មោះ[redacted]ធីយីវ ភេទស្រី អាយុ២២ឆ្នាំ ជាតិវៀតណាម

ខ-ឈ្មោះ [redacted] ហុងវីង ភេទប្រុស អាយុ២០ឆ្នាំ ជាតិវៀតណាម

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន១៧ឆ្នាំ "ដប់ប្រាំពីរឆ្នាំ" គិតចាប់ពីថ្ងៃចាប់ខ្លួន ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦។

គ-ឈ្មោះ [redacted] ទី ភេទស្រី អាយុ៤៨ឆ្នាំ ជាតិវៀតណាម ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ "ដប់ប្រាំឆ្នាំ" គិតចាប់ថ្ងៃចាប់ខ្លួនថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦។

ឃ-ឈ្មោះ [redacted] Heninz ភេទប្រុស អាយុ៦០ឆ្នាំ ជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់១៦ឆ្នាំ "ដប់ប្រាំមួយឆ្នាំ" គិតចាប់ពីថ្ងៃ ចាប់ខ្លួនថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦។

ពីបទ៖ ជួញដូរមនុស្ស ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែ០៧, ០៨ ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស។

២/-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] Heninz ភេទប្រុស អាយុ៦០ឆ្នាំ ជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ"ដប់ពីរឆ្នាំ" គិតចាប់ពីថ្ងៃផុតកំណត់ទណ្ឌកម្មនៃបទល្មើសក្នុងចំណុច១ ខាងលើនេះ។

ខ-ឈ្មោះ[redacted] Thomas ភេទប្រុស អាយុ៤២ឆ្នាំ ជាតិអាឡឺម៉ង់ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ "ដប់ពីរឆ្នាំ" គិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦។

ពីបទ៖ ប្រព្រឹត្តអំពើអនាចារលើកុមារ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីខែ០៧,០៨ ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើធ្វើអាជីវកម្មលើមនុស្ស។

៣/-វត្ថុតាង៖

ក-លិខិតឆ្លងដែនមានលេខ ១/៣៣៤៥០០៥៤៤០, ២/៩៥០៦៣៧៥៧៣៥, ៣/១០៣២១៣៦៨៤០, ៤/១០៣២០៧៧៤៥, ៥/១០៣២០៩៨៥៤៨, ៦/១៣១០២៨៤៤០១ លិខិតឆ្លងដែនចំនួន០៦ក្បាល ត្រូវប្រគល់អោយសាម៉ីខ្លួនវិញ ក្រោយពេលផុតកំណត់ទណ្ឌកម្មរួច។

ខ-VCD, CD កាសែត Mini DV លេខ៦០ ម៉ាក Sony ចំនួន៤៣ដុំ, ខ្សែពណ៌ស ប្រវែង០៥ម៉ែត្រ "ប្រាំម៉ែត្រ" មួយខ្សែ, ខ្សែពណ៌ផ្កាឈូកប្រវែង០២ម៉ែត្រ "ពីរម៉ែត្រ" មួយខ្សែ,

120



Scanned by CamScanner

រំពាត់ស្បែកចំនួនមួយ, លិង្គសិប្បនិម្មិតចំនួន០៦, ថ្នាំម៉ាកKY១ដប, សៀវភៅរូបអាសអាភាសមួយចំនួន, ហ្វីលរូបអាសអាភាសមួយចំនួន, ស្រោមអនាម័យមួយចំនួនត្រូវរឹបអូស និងបំផ្លាញចោល។

គ-ម៉ាស៊ីនថតរូបម៉ាក Kodark ចំនួនមួយ, កាមេរ៉ាថតវីដេអូម៉ាក Sony 1.5 Magapixel ចំនួនមួយ, PC Card ចំនួនមួយ, ម៉ាស៊ីនថតរូបម៉ាក Olympus ចំនួនមួយ, Platininnum card ចំនួនមួយ, ID card ចំនួនមួយ, ម៉ាស៊ីនថតវីដេអូម៉ាកសូនីចំនួនមួយ, ទូរស័ព្ទដៃម៉ាកណូគារចំនួនមួយ ធុងបាស់តូចម៉ាក Nicole ចំនួនពីរ, ម៉ូនីទ័រម៉ាក Socos ចំនួនមួយ, CD Rom code DVR ចំនួនមួយ, ឌីសកុំព្យូទ័រ៣០បន្ទះ, ប្រដាប់ទប់ភ្លើងកុំព្យូទ័រចំនួនមួយត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជំរះនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧, ០៩ ខែមីនា ឆ្នាំ២០០៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧ ចំពោះមុខជនជាប់ចោទ, ជនរងគ្រោះ និងមេធាវី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១១៧ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted]Karl Opitz, [redacted] ឌី, [redacted]ធីយ៉ែរ, [redacted] ហុងវីង និងបណ្តឹងឧទ្ធរណ៍លេខ១៤០ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៧ របស់ឈ្មោះ BORON [redacted] [redacted]HOMS ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៤ "ខ" ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសាលក្រមនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា:

១-ទទួលពាក្យបណ្តឹងរបស់ជនជាប់ចោទឈ្មោះ [redacted]យ៉ែរ[redacted] ឌី, [redacted] ហុងវីង និងឈ្មោះ [redacted]Opitz, ឈ្មោះ [redacted]E[redacted]T THOMAS ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្លូវគតិច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៤៤"ខ" ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការ។

៣-សុំឱ្យឃុំខ្លួនបន្តជនដែលត្រូវឃុំខ្លួន។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨៥ "ក" ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច:

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted]homas បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted]Heninz ឈ្មោះ[redacted] ឌី,ឈ្មោះ [redacted]ធីយ៉ែរ និងឈ្មោះ [redacted]ហុងវីង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

98/8

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៤៤ "ខ" ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧ របស់សាលាដំបូងក្រុងភ្នំពេញទុកជាបានការពេញទាំងមូល ដោយគ្រាន់តែកែតម្រូវក្នុងចំណុចទី១ នូវបទល្មើសជួញដូរមនុស្សមកជាបទល្មើសលក់ទិញដូរមនុស្សដោយមានគោលដៅ តាមមាត្រា១៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបទសញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ តាមមាត្រា ២៨ នៃច្បាប់ដដែល ព្រមទាំងកែតម្រូវក្នុងចំណុចទី២ នូវបទប្រព្រឹត្តអំពើអនាចារលើកុមារមកជាបទទិញពេស្យាចារកុមារវិញ តាមមាត្រា៣៤ នៃច្បាប់ដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted]eninz, [redacted] Lhardt Thomas ឈ្មោះ[redacted] ធីយ៉ីវ, ឈ្មោះ [redacted]ហុងវីង និងឈ្មោះ[redacted]ទី។

៤-សាលដីកានេះជំនុំជំរះជាអសាធារណៈនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] Thomas និងឈ្មោះ [redacted] ហុងវីង និងមេធាវីការពារ កំបាំងមុខ ជនជាប់ចោទឈ្មោះ [redacted]Heninz, ឈ្មោះ [redacted] ធីយ៉ីវ និងឈ្មោះ[redacted]ទី ចំពោះមុខជនរងគ្រោះ[redacted] ចាន់ថា,[redacted] ចាន់ធី និង[redacted]ធីគីមធី និងមេធាវីការពារ ប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ បើកផ្លូវប្តឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងទាស់លេខ៥៨ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted] ធីយ៉ីវ, [redacted] ទី និងឈ្មោះ[redacted]Heninz ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៨៥ "ក" ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤១ "ក" ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចៈ

១-ទទួលបណ្តឹងទាស់ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ធីយ៉ីវ, ឈ្មោះ [redacted] Heninz, ឈ្មោះ[redacted]ទី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៥ "ក" ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted]Heninz, ឈ្មោះ[redacted] ធីយ៉ីវ, ឈ្មោះ [redacted]ហុងវីង និងឈ្មោះ [redacted]ទី។

៤-សាលដីកានេះជំនុំជំរះជាអសាធារណៈ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]Heninz, ឈ្មោះ[redacted]ធីយ៉ីវ និងឈ្មោះ[redacted] ទី មេធាវី



Scanned by CamScanner

ការពារជនជាប់ចោទ និងមេធាវីការពារជនរងគ្រោះប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៣២២ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ហុងវីង និងបណ្តឹងសាទុក្ខលេខ៥៩ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] Karl Opitz, [redacted] ទី, [redacted] ធីយីវ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៤១ "ក" ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ត្រង់ចំនុចនៃសេចក្តីសំរេចទាំងមូល។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា៖

១-ទទួលពាក្យបណ្តឹងសាទុក្ខលេខ៣២២ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ហុងវីង និងបណ្តឹងសាទុក្ខលេខ៥៩ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ទី, [redacted] ធីយីវ និងឈ្មោះ [redacted] Heninz ទុកជាត្រឹមត្រូវតាមទម្រង់ ប៉ុន្តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤១ "ក" ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល និងពិចារណាតាមមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌ ទាក់ទងនឹងការចោទប្រកាន់តែមួយ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្តាប់សាវតាជាតិ និងចំលើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] ធីយីវ នាពេលសវនាការថា៖ ហេតុអ្វីបានជាអ្នកឯងមិនសុខចិត្តនឹងសាលដីកាសាលាឧទ្ធរណ៍? ខ្លួនមិនសុខចិត្តព្រោះគេថាខ្លួនលក់ស្រីទៅឱ្យឈ្មោះ [redacted] នឹង តាមពិតខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ខ្លួនគ្រាន់តែជាអ្នកសំអាតផ្ទះឱ្យ [redacted] នឹង ពេលគេចាប់ខ្លួន [redacted] នឹង គេក៏ចាប់ខ្លួនដែរ ហើយចោទខ្លួនថា ជាអ្នកទិញស្រីឱ្យ ហេន នឹង ទៀត។ តាមពិតខ្លួនមកធ្វើការនៅផ្ទះនេះមានរយៈពេលជិត១ឆ្នាំហើយ តែធ្វើការ១ថ្ងៃពី ២ទៅ៣ម៉ោងប៉ុណ្ណោះ ក៏ត្រឡប់ទៅផ្ទះវិញ ក្នុងការសំអាតផ្ទះនេះដែរ ២ទៅ៣អាទិត្យ ទើបខ្លួនមកសំអាតម្តង ហើយក៏មិនធ្លាប់រកស្រីឱ្យឈ្មោះ ហេន នឹង ដែរ។ ចំពោះក្មេងស្រីៗដែលខ្លួនបានឃើញនោះ មានអាយុទើប១៣ឆ្នាំ ទៅ១៤ឆ្នាំ។ ពីមុនមកខ្លួនធ្វើជាស្រីនៅស្វាយប៉ាក ហើយក៏ធ្លាប់ជួប ថូ មាស់ ដែរ តែនៅផ្ទះ ហេន នឹង ខ្លួនមិនធ្លាប់ជួបទេ។

សំណូមពរ៖ សូមឱ្យតុលាការកំពូលសំរេចដោះលែងខ្លួន ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

-បានស្តាប់សាវតាជាតិ និងចំលើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] ទី នាពេលសវនាការថា៖ តើអ្នកឯងប្តឹងសាទុក្ខមិនសុខចិត្តពីសាលដីកាលើចំណុចណា? ខ្លួនមិនសុខចិត្តដោយ



Scanned by CamScanner

98/6

ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្លួនក៏ពុំបានស្គាល់ឈ្មោ[redacted]ធីយ និងឈ្មោះ [redacted] ហុងវីងដែរ តែខ្លួនពិតជាបានស្គាល់ឈ្មោះ [redacted] ចាន់ធី, [redacted] ចាន់ថា ព្រោះអ្នកទាំងពីរជាកូនរបស់ខ្លួន ហើយកូនខ្លួនបានទៅរៀននៅជិតផ្ទះរាល់ថ្ងៃ។ កូនខ្លួនមិនដែលដើរចោលផ្ទះ ២ ទៅ៣ម៉ោងទេ។ ចំពោះកូនខ្លួនទៅផ្ទះ ហេន នឹង នោះ ខ្លួនមិនដែលបានយកកូនទៅបំរើផ្លូវភេទនៅផ្ទះ ហេន នឹង ទេ។ ចំពោះអាកប្បកិរិយាកូនៗវិញ ខ្លួនមិនដែលបានចាប់អារម្មណ៍ទេ និងក្មេងៗពីរនាក់ទៀតខ្លួនមិនស្គាល់ទេ។ បច្ចុប្បន្ននេះ កូនខ្លួនបានទៅរៀតណាមវិញហើយ ប្តីខ្លួនក៏ទៅវៀតណាមដែរ។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ Henning នាពេលសវនាការថា៖ មុនពេលចាប់ខ្លួនស្ថិតនៅក្រោយផ្សារឡាក់គី ផ្លូវ១៨១ ទល់មុខសណ្ឋាគារតូក្យូ កាលពីមុនជាគ្រូបង្រៀន នៅប្រទេសអាឡឺម៉ង់ ផ្នែកពេទ្យ ហើយចាប់ខ្លួននៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៦។ តើអ្នកឯងប្តឹងសាទុក្ខមិនសុខចិត្តពីសាលដីកាសាលាឧទ្ធរណ៍លើចំណុចណាខ្លះ? ខ្លួនសុំបដិសេធពីបទជួញដូរកុមារ និងការធ្វើទារុណកម្មបង្ខាំងកុមារីរងគ្រោះនោះទេ។ ខ្លួនគ្រាន់តែធ្លាប់បានជួបមនុស្សមួយចំនួនដែលរកស៊ីផ្លូវភេទនៅស្វាយប៉ាកពេលដែលខ្លួនទៅលេងផ្ទះមិត្តភ័ក្រ។ ខ្លួនដឹងថានារីមួយចំនួនរកស៊ីផ្លូវភេទ ខ្លួនសារភាពថាខ្លួនធ្លាប់រួមភេទជាមួយឈ្មោះ [redacted] ចាន់ថា ខ្លួនមិនដែលយកព្រហ្មចារីរបស់នារីណាម្នាក់នៅក្នុងអាផាតមិនរបស់ខ្លួនទេ។ ខ្លួនមិនបានសួរអាយុក្មេងស្រីដែលខ្លួនរួមភេទនោះទេ។ ខ្លួនពិតជាមិនបានសួរអាយុពិតមែន ហើយក៏ពិបាកវាយតម្លៃ អាយុមនុស្សដែរ។ អាយុដែលអាចរួមភេទបាននៅប្រទេសកម្ពុជា ខ្លួនមិនដឹងទេ តែអាយុដែលអាចរួមភេទបាននៅប្រទេសអាឡឺម៉ង់គឺអាយុ១៤ឆ្នាំឡើង។ ខ្លួនសុំទទួលខុស បើខ្លួនបានរំលោភបំពានច្បាប់នៅទីនេះ។ ហើយសុំអះអាងថា រូបថតនៅក្នុងសំណុំរឿងនេះ ខ្លួនមិនដែលថតទេហើយក៏មិនដែលបានបង្ហោះរូបតាមអ៊ីនធឺណេតដែរ និងលោកស្រីដែលជាជនជាប់ចោទក៏មិនបានរកស្រីឱ្យខ្លួនដែរ។ ខ្លួនស្គាល់នារីមួយចំនួននៅស្វាយប៉ាក មកលែងកំព្យូទ័រនៅផ្ទះខ្លួន ហើយពួកគេតែងតែហៅគ្នាមកលេងទីនេះជាប្រចាំ ហើយខ្លួនក៏ត្រូវការមនុស្សច្រើនដែរ។ ខ្លួនជាមនុស្សចាស់មិនអាចរួមភេទបាន១០ទៅ២០ដងនោះទេ រឿងមកលេងផ្ទះខ្លួននេះប្រហែលជាផ្ទះខ្លួនស្អាតហើយមើលទៅ។ ឈ្មោះ ថូ ម៉ាស់ ខ្លួនស្គាល់គាត់យូរហើយ ព្រោះឈ្មោះ ថូ ម៉ាស់ នេះចេះកុំព្យូទ័រច្រើនជាងខ្លួន ហើយឃើញក្មេងស្រីមកលេងផ្ទះខ្លួនច្រើន ទើប ថូ ម៉ាស់ មកលេងដែរ ដោយបានថតរូបទៀតផង។ ចំពោះក្មេង ស្រីក្នុងរូបថត ដែលក្រុមប្រឹក្សាសួរនេះ មិនទាន់គ្រប់អាយុនៅឡើយទេ ចំពោះប្រទេសកម្ពុជា។ ខ្លួនសង្ឃឹមថាតុលាការកំពូលនឹងកែតម្រូវ ហើយខ្លួនសុំសារភាពខ្លួនធ្លាប់រួមភេទជាមួយក្មេងមិនទាន់គ្រប់អាយុ តែខ្លួនមិនដែលធ្វើទារុណកម្ម និងបង្ខាំងកុមារនោះទេ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] វិមានចំប៉ា មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ធី និ[redacted] ហុងវីង នាពេលសវនាការថា: កូនក្តីខ្លួនបានបដិសេធថា ខ្លួនមិនបាន

124



Scanned by CamScanner

ប្រព្រឹត្តដូចការចោទប្រកាន់ទេ កូនក្តីខ្ញុំទៅធ្វើការ ចំណែកកូនទៅផ្ទះតែខ្ញុំមិនដឹងថាទៅណាទៀតទេ ក្រោយមកទើបដឹងថាទៅស៊ីឈ្នួលរត់តុលាងចានឱ្យគេ។ កូនក្តីខ្ញុំមិនស្គាល់ជនជាប់ចោទផ្សេងទៀតទេ កូនក្តីខ្ញុំស្ថិតក្នុងវិមតិសង្ស័យតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងតាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។

សំណូមពរ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទប្រកាន់។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] យក់ហៀប មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ Henning និងឈ្មោះ [redacted] ធីយីវ នាពេលសវនាការថា:ដោយមិនសុខចិត្តនឹងសាលក្រម, សាលដីកា ទើបកូនក្តីខ្ញុំប្តឹងសាទុក្ខ កូនក្តីខ្ញុំឈ្មោះ Henning បានស្គាល់កូនក្តីខ្ញុំមួយទៀតឈ្មោះ [redacted] ធីយីវ ជាយូរមកហើយ ព្រោះពីមុន [redacted] ធីយីវ ធ្វើការនៅស្វាយប៉ាក ហើយមានជំងឺឈ្មោះ Henning បានឱ្យលុយយកមកព្យាបាលជំងឺ។ ឯឈ្មោះ ថូ ម៉ាសវិញ ក៏បានមកលេងផ្ទះកូនក្តីខ្ញុំឈ្មោះ Henning និងរួមទាំងក្មេងស្រីៗក៏មកលេងហ្គេមនៅផ្ទះនេះ ហើយកូនក្តីខ្ញុំឈ្មោះHenning នេះធ្លាប់រួមភេទជាមួយក្មេងស្រីឈ្មោ[redacted]ចាន់ថា ដោយឈ្មោះនេះបានខូចព្រហ្មចារីរួចហើយមុននឹងមករួមភេទជាមួយកូនក្តីខ្ញុំ ពេលនោះកូនក្តីខ្ញុំក៏មិនបានសួរពីអាយុក្មេងស្រីនេះដែរ។ កូនក្តីខ្ញុំបានទទួលកំហុសនឹងច្បាប់កម្ពុជា និងសុំឯកភាពតាមលោកព្រះរាជអាជ្ញាលើមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ។

សំណូមពរ សុំបង្វិលសំណុំរឿង និងបដិសេធសាលដីកាសាលាឧទ្ធរណ៍។

-ចំពោះឈ្មោះ[redacted] ធីយីវវិញធ្លាប់ស្គាល់ឈ្មោះ Henning ដោយឈ្មោះនេះធ្លាប់បានឱ្យប្រាក់ទៅឈ្មោះ[redacted] ធីយីវទៅព្យាបាលជំងឺហើយក៏មិនដែលនាំក្មេងស្រីឱ្យឈ្មោះ Hennnigដែរ។ កូនក្តី ខ្ញុំគ្មានបទល្មើសទេ សុំបដិសេធចម្លើយនៅប៉ូលីសដោយគ្មានអ្នកបកប្រែភាសា។

សំណូមពរ សុំឱ្យតុលាការកំពូលដោះលែងកូនក្តីខ្ញុំឱ្យនៅក្រៅឃុំ ព្រោះកូនក្តីខ្ញុំជាប់ពន្ធនាគារចំនួន៧ឆ្នាំហើយ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ធីយីវ ថាខ្លួនបាននាំក្មេងស្រីទៅលេងហ្គេមចំនួន១០ដង, ឈ្មោះ [redacted] ធីយីវ និងឈ្មោះ[redacted]ហុងវីង ថាបានឌុបក្មេងស្រីទៅលេងហ្គេមនៅផ្ទះឈ្មោះ Henning ហើយឈ្មោះនេះបានឱ្យលុយខ្លួនចំនួន ៣០០ដុល្លា, ឈ្មោះ [redacted]ធី ថាខ្លួនស្គាល់ឈ្មោះ[redacted]ធីយីវដែរ ហើយខ្លួនពិតជាបានឱ្យកូនទៅឈ្មោះ[redacted] ធីយីវ លក់ព្រហ្មចារីឱ្យឈ្មោះ Henning ពិតមែន។

ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជំរះពិចារណាលើចម្លើយទាំងនេះ និងតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការដដែល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

៤៥

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣២២ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]ុងវីង និងបណ្តឹងសាទុក្ខលេខ៥៩ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០របស់ឈ្មោះ[redacted]ទី, [redacted] ធីយ័រ, និងឈ្មោះ [redacted] OPITZ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា នាពេលសវនាការនៅតុលាការកំពូល ជនជាប់ចោទឈ្មោះ [redacted]ធីយ័រ និងឈ្មោះ [redacted] ទី ឆ្លើយថាខ្លួនមិនបានប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់ទេ ដូច្នេះសុំតុលាការកំពូល សម្រេចដោះលែងពួកខ្លួនឱ្យមានសេរីភាព នោះតុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះថា៖ តាមកំណត់ហេតុសួរចម្លើយចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ របស់មន្ត្រីនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ក៏ដូចកំណត់ហេតុសួរចម្លើយចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ របស់អយ្យការអមតុលាការក្រុងភ្នំពេញ និងកំណត់ហេតុសួរចម្លើយចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងភ្នំពេញដែរ ជនជាប់ចោទឈ្មោះ [redacted]យ័រ បានឆ្លើយសារភាពថាខ្លួនធ្លាប់យកក្មេងស្រីឈ្មោះ ថា និងឈ្មោះ ធី ទៅឱ្យជនជាប់ចោទឈ្មោះ Henning។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]ធីយ័រនេះ មានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់កុមារីជនរងគ្រោះឈ្មោះ [redacted]ាន់ធី និងឈ្មោះ[redacted]ាន់ថា ដែលបានឆ្លើយនៅក្នុងកំណត់ហេតុសាកសួរបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននិងកំណត់ហេតុសួរចម្លើយចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងភ្នំពេញដែលថា ជនជាប់ចោទឈ្មោះ [redacted] ធីយ័រ បាននាំពួកខ្លួនទៅរួមភេទជាមួយជនបរទេសឈ្មោះ Henning។ បន្ទាប់ពីរួមភេទរួច ឈ្មោះ [redacted] ធីយ័រ បានឱ្យលុយពួកខ្លួនទៀតផង។ ចំណែកឯជនជាប់ចោទឈ្មោះ[redacted] ទី ដែលជាម្តាយបង្កើតរបស់កុមារីជនរងគ្រោះឈ្មោះ[redacted]ចាន់ធី និងឈ្មោះ [redacted]ចាន់ថា បានឆ្លើយនៅចំពោះមុខសវនាការនៃតុលាការកំពូលថា ខ្លួនពុំបានលក់កូនរបស់ខ្លួនឈ្មោះ [redacted]ចាន់ធី និ[redacted]ចាន់ថា ឱ្យឈ្មោះ Henning ទេ ប៉ុន្តែខ្លួនបានទទួលលុយពីកូនម្តងមួយម៉ឺន ឬពីរម៉ឺនរៀល ហើយប្រាក់នេះកូនរបស់ខ្លួនប្រាប់ថា បានមកពីជួយលាងចាននៅហាង លក់គុយទាវ កាហ្វេ ចំណុចនេះតុលាការពុំ

98
3

ពិចារណាបានទេ ពីព្រោះតាមកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ កុមារីជនរងគ្រោះឈ្មោះ [redacted] ចាន់ថា បានឆ្លើយថាខ្លួនបានរួមភេទជាមួយឈ្មោះ Henning មួយអាទិត្យ ដោយបានទទួលប្រាក់ចំនួន៥០០ដុល្លា ពីឈ្មោះ យីវ ហើយប្រាក់នេះខ្លួនបានយកទៅឱ្យម្តាយ និងឪពុកខ្លួន។ ដូច្នេះអង្គហេតុនេះបញ្ជាក់ឱ្យឃើញថា បើគ្មានការយល់ព្រមពីម្តាយឪពុកទេ កុមារីឈ្មោះ [redacted] ចាន់ថា ជាអនីតិជន មិនអាចអវត្តមាន ពីផ្ទះរយៈពេលមួយអាទិត្យដោយគ្មានការព្រួយបារម្ភពីអាណាព្យាបាលនោះបានទេ។ លើសពីនេះទៅទៀត តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហុងវីង ដែលជាប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] យីវ បានឆ្លើយនៅក្នុងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៦ របស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចនៅចំពោះមុខតំណាងអយ្យការ និងចៅក្រមស៊ើបអង្កេតរបស់តុលាការក្រុងភ្នំពេញថា ខ្លួន និងប្រពន្ធខ្លួនឈ្មោះ [redacted] ធីយីវ បានទៅយកកុមារីឈ្មោះ [redacted] ចាន់ធី និងឈ្មោះ [redacted] ចាន់ថា ពីផ្ទះនៅច្រាំងបាក់ឡាអំពៅ មកឱ្យជនជាប់ចោទឈ្មោះ Henning នៅផ្ទះក្រោយផ្សារឡូកំពី។ ដូច្នេះឃើញថា មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ធីយីវ, [redacted] ទី និងឈ្មោះ [redacted] ហុងវីង ពីអំពើលក់ដូរមនុស្សដោយមានគោលដៅ និងសញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ តាមមាត្រា ១៥ និងមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដូចការចោទប្រកាន់របស់តុលាការអង្គសេចក្តីប្រាកដមែន។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ៤៤"ខ" ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ដោយគ្រាន់តែកែតម្រូវចំណុចទី២ នៃសាលក្រម គឺពីបទជួញដូរមនុស្ស មកជាបទលក់-ទិញដូរមនុស្ស ដោយមានគោលដៅតាមមាត្រា ១៥ និងបទសញ្ចារកម្មទាក់ទងនឹងពេស្យាចារតាមមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនោះជាការត្រឹមត្រូវហើយ ពីព្រោះថា តាមចម្លើយរបស់កុមារីដែលជាជនរងគ្រោះបានឆ្លើយថា ខ្លួនបានរួមភេទជាមួយជនជាប់ចោទឈ្មោះ Henning ក្រោយពីការរួមភេទរួច ខ្លួនបានទទួលលុយពីជនជាប់ចោទឈ្មោះ [redacted] ធីយីវ ហើយលុយនេះខ្លួនយកទៅអោយម្តាយនិងឪពុក ហេតុនេះការកំណត់បទល្មើសថ្មីនេះត្រឹមត្រូវជាង។ ប៉ុន្តែការដែលសាលាឧទ្ធរណ៍កំណត់បទល្មើស ដូចគ្នាលើជនជាប់ចោទឈ្មោះ [redacted]z OPITZ តាមមាត្រា ១៥ និង២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នោះជាការមិនត្រឹមត្រូវទេ ពីព្រោះថា៖ មាត្រា ១៥ កំណត់ថាបទល្មើសនេះ គឺជនណាដែលលក់ដូរជនដទៃ ដោយមានគោលដៅស្វែងរកប្រយោជន៍ល្មោភពានខាងផ្លូវភេទ, ផលិតរូបភាពអាសអាភាស, រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ,សុំកូន,



Scanned by CamScanner

ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត។ រីឯបទសញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារដែលមានចែងក្នុងមាត្រា ២៨ នៃច្បាប់ខាងលើនេះឱ្យនិយមន័យលើពាក្យសញ្ញារកម្មថា៖

១-ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ

២-ជួយ ឬការពារអំពើពេស្យាចាររបស់ជនដទៃ

៣-ជ្រើសរើសអូសទាញ ឬបណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ

៤-ធ្វើការគៀបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ។

ដូច្នេះ បើពិនិត្យមើលភស្តុតាងជាឯកសារនៅក្នុងសំណុំរឿង និងចម្លើយរបស់កុមារីជនរងគ្រោះឃើញថា ជនជាប់ចោទឈ្មោះ Henning បានរួមភេទជាមួយកុមារីរងគ្រោះទាំងអស់បានតាមរយៈអន្តរការី គឺជនជាប់ចោទឈ្មោះ [redacted] ធីយ៉ារ និងឈ្មោះ [redacted] ហុងរីង ដែលប្រើវិធីលួងលោមដោយបញ្ចុះបញ្ចូលទៅញ៉ាំបង្អែម, ការ៉េម, លេងហ្គេមនៅផ្ទះរបស់ជនជាប់ចោទនៅក្រោយផ្សារឡូត៍គី។ លើសពីនេះទៀតជនជាប់ចោទឈ្មោះ [redacted] ធីយ៉ារ នេះភាសាខ្មែរជួយបកប្រែក្នុងពេលកុមារីរួមភេទជាមួយជនជាប់ចោទឈ្មោះ Henning ទៀតផង។ បន្ទាប់ពីការរួមភេទឈ្មោះ [redacted] ធីយ៉ារ បានឱ្យលុយទៅកុមារីជនរងគ្រោះ ហើយលុយនេះកុមារីជនរងគ្រោះបានយកទៅឱ្យម្តាយឈ្មោះ [redacted] ធី។ ចំណែកឯរូបថតដែលមានក្នុងសំណុំរឿង នាពេលសវនាការរបស់តុលាការកំពូល ជនជាប់ចោទឈ្មោះ Henning បានបដិសេធថា ខ្លួនជាគ្រូបង្រៀនភាសាអង់គ្លេស ហើយគ្មានជំនាញខាង Computerទេ រូបថតនេះគឺឈ្មោះ Thomas ជាអ្នកថតទេ ហើយខ្លួនក៏ពុំបានបង្ខាំង ឬបង្ខិតបង្ខំឱ្យកុមារីជនរងគ្រោះដើម្បីរួមភេទទេ តែបានទទួលស្គាល់ថាខ្លួនពិតជាបានរួមភេទជាមួយកុមារីជនរងគ្រោះជាអនីតិជនដោយការស្ម័គ្រចិត្តពិតមែន។ ភស្តុតាងជាក់ស្តែងទាក់ទងនឹងឈ្មោះ Henning គឺមានលក្ខណៈគ្រប់គ្រាន់ជាបទ ការទិញពេស្យាចារកុមារ បទល្មើសដែលមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប៉ុណ្ណោះ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៤១ "ក" ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះត្រូវខ្លះខុសខ្លះ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-បដិសេធបណ្តឹងសាទុក្ខលេខ៣២២ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ហុងរីង និងលេខ៥៩ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ធីយ៉ារ។

២-ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ៥៩ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] OPITZ។



Scanned by CamScanner

98/1

៣-តម្កល់សាលដីកាសភាស៊ើបសួរលេខ៤១ "ក" ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលសម្រេចតម្កល់សាលដីកាកំណត់មុខលេខ៨៥ "ក" ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ដែល លើកលែងតែត្រង់ចំណុចទី២ នៃសាលដីកាដែលផ្តន្ទាទោស ឈ្មោះ [redacted] OPITZ ពីបទៈ ជួញដូរមនុស្សដោយមានគោលដៅ តាមមាត្រា ១៥ និងបទសញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ តាមមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលត្រូវបដិសេធចោល។

៤-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៩០ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះឡើងវិញលើចំណុចខាងលើ។

៥-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី 30 ខែតុលា ឆ្នាំ២០១៣

ក្រឡាបញ្ជី

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣

ជ.ប្រធានតុលាការកំពូល

អនុប្រធាន



Scanned by CamScanner